# ទស្សនៈ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីវប្បធម៌ថៃរបស់ណាគួរឲ្យនាំចូលនិងរបស់ណាដែលមិនត្រូវនាំចូលមកប្រទេសកម្ពុជា

web site: hoksavann.org

ថ្ងៃទី៥ កុម្ភៈ ២០០៥

សារាចរមួយចុះថ្ងៃទី២៨ធ្នូ២០០៤របស់សម្តេចទេព-វង្ស បានប្រកាសហាមព្រះសង្ឃខ្មែរបកប្រែគម្ពីរអដ្ឋកថាដីកានៃព្រះត្រៃបិដករបស់ថៃមកជាភាសាខ្មែរ និងនាំគម្ពីរទាំងនោះចូលមកប្រទេសកម្ពុជា ។ មួយទៀតហាមនាំព្រះសារីរិកធាតុនៃព្រះពុទ្ធពីបរទេសចូលមកប្រទេសកម្ពុជា ។

តាមយោបល់យើង វត្ថុខ្លះគួរហាម វត្ថុខ្លះពុំគួរហាមទេ ។ វត្ថុដែលគួរហាមនោះមានព្រះពុទ្ធរូប ព្រោះព្រះពុទ្ធរូបរបៀបថៃមានលក្ខណៈខុសគ្នាពីរបៀបខ្មែរ ការហាមឃាត់មិនឲ្យនាំចូលជាការត្រឹមត្រូវ ព្រោះខ្មែរមានសមត្ថភាពនិងមានលទ្ធភាពធ្វើខ្លួនឯងបានហើយ បន្ទាប់ពីបញ្ចប់សង្គ្រាមក្នុងប្រទេស ។ ការនិយមប្រើប្រាស់បូជនីយវត្ថុ គឺព្រះពុទ្ធរូបរបស់ជាតិខ្លួន ជាការលើកតម្កើងវប្បធម៌ជាតិ ហើយអាចរក្សាលក្ខណៈនៃព្រះពុទ្ធរូបរបៀបខ្មែរឲ្យស្ថិតនៅជានិច្ចហើយរូបិយប័ណ្ណមិនធ្លាក់ទៅបរទេស ។ ការកសាងព្រះពុទ្ធរូបនិងលក់ដូរនៅក្នុងស្រុក នាំឲ្យខ្មែរមានការងារធ្វើ ។ ចំណែកស្បង់ចីពរនិងផលិតផលផ្សេងៗទៀតរបស់ព្រះពុទ្ធសាសនា បើអាចផលិតនៅក្នុងប្រទេសកម្ពុជាបាន ក៏ពុំគួរឲ្យនាំចូលមកប្រទេសកម្ពុជាដែរ។ ការពុំនាំពិធីរបស់ថៃ គឺពិធីកម្មក្នុងព្រះពុទ្ធសាសនា មានពិធីធ្វើបុណ្យទានផ្សេងៗ មានពិធីសូត្រធម៌ជាដើម ទោះប្រទេសខ្មែរនិងប្រទេសថៃកាន់ព្រះពុទ្ធសាសនាថេរវាទដូចគ្នា ប៉ុន្តែរបៀបពិធីកម្មមានលក្ខណៈផ្សេងគ្នាតាមលក្ខណៈជាតិរៀងខ្លួន ។ បើមិនឲ្យនាំចូលសៀវភៅបែបនេះក៏គ្មានអ្នកជំទាស់ដែរ ដើម្បីកុំឲ្យពុទ្ធសាសនិកជនខ្មែរ មានព្រះសង្ឃជាដើមចម្លងធ្វើតាម ព្រោះមានសង្ឃខ្មែរមួយភាគតូច ទៅរស់នៅប្រទេសថៃយូរ លុះត្រឡប់មករស់នៅក្នុងសង្គមខ្មែរវិញនៅបរទេស បានចម្លងពិធីកម្មរបស់ថៃខ្លះ មកអនុវត្តក្នុងសង្គមរបស់ខ្លួន ។ ប៉ុន្តែបើខ្មែរមានទំនៀមទំលាប់រឹងមាំហើយ ទោះបីនាំចូលក៏ខ្មែរពុំទទួលធ្វើតាមឡើយ ។ មួយទៀត ដើម្បីចំណេះដឹង សៀវភៅដែលទាក់ទងនឹងការសិក្សាត្រូវតែមើល ពុំមែនមើលដើម្បីជឿឬអនុវត្តតាមទេ តែដើម្បីការចេះដឹង ។ បញ្ហាមួយទៀត ថៃមាននិកាយមួយមានឥទ្ធិពលយ៉ាងខ្លាំងនៅប្រទេសថៃ ប៉ងនាំចូលមកបង្កើតនៅប្រទេសកម្ពុជា តែត្រូវព្រះសង្ឃខ្មែរប្រឆាំង និកាយនេះមានឈ្មោះថា <ធម្មកាយ> ។ ការមិនអនុញ្ញាតឲ្យ <ធម្មកាយ> របស់ថៃមកបង្កើតនៅប្រទេសកម្ពុជា នេះជាការត្រឹមត្រូវ សូមគាំទ្រគំនិតដ៏ប្រពៃនេះ ដើម្បីកុំឲ្យព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា បែកជាគណៈនិកាយផ្សេងទៀត នាំឲ្យខ្មែរបែកសាមគ្គីគ្នា ។

បញ្ហាមួយក្រៅពីនេះដែលគួរពិចារណានោះ គឺត្រង់អដ្ឋកថាដីកានៃព្រះត្រៃបិដកថៃដែលមានច្រើន ចំណែកខ្មែរមានចំនួនតិចនៅខ្វះខាត គួរឲ្យនាំចូលមកប្រទេសកម្ពុជាសម្បូរណ៍ឯកសារព្រះពុទ្ធសាសនា ព្រោះអដ្ឋកថាដីកា ដែលថៃមានច្រើននោះ ពុំមែនជាទំនៀមទំលាប់របស់ថៃទេ គឺជាឯកសារព្រះពុទ្ធសាសនាសុទ្ធសាធ ព្រោះអដ្ឋកថាដីកាទាំងនេះ កើតឡើងដោយព្រះអរហន្ត អធិប្បាយពន្យល់តាមព្រះពុទ្ធដីកា ដោយពង្រីកសេចក្តីឲ្យងាយយល់ ពុំមែនជាគំនិតរបស់ថៃទេ ។ ការបិទគម្ពីរអដ្ឋកថាដីកា ដែលអធិប្បាយអំពីគម្ពីរព្រះត្រៃបិដកថៃរបស់សម្តេចទេព-វង្ស មិនឲ្យប្រែនិងមិនឲ្យនាំចូលមកប្រទេសកម្ពុជានេះ ពុំសមរម្យទេ ព្រោះប្រទេសកម្ពុជាខ្វះឯកសារព្រះពុទ្ធសាសនាជាច្រើន ជាពិសេសផ្នែកអដ្ឋកថាដីកានេះ គួរឲ្យបកប្រែដើម្បីការលូតលាស់នៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ពុំប៉ះពាល់ដល់ទំនៀមទម្លាប់ខ្មែរឡើយ ។ ចំពោះព្រះសារីរិកធាតនៃព្រះពុទ្ធវិញ ក៏ពុំគួរមានតែមួយកន្លែងដែរ ។ បើធ្វើទីកន្លែងបូជនីយដ្ឋានសំរាប់ដំកល់ត្រឹមត្រូវ ហើយព្រះធាតុដែលបានមកជាព្រះធាតុពិតដែលគួរជឿបាន មិនត្រូវហាមឃាត់ទេ ត្រូវឲ្យមានច្រើនកន្លែងក្នុងប្រទេសកម្ពុជា ព្រោះដើម្បីឲ្យពុទ្ធបរិស័ទខ្មែរនៅជិតនោះគោរពបូជា ប្រសើរមានតែមួយកន្លែង ប្រជាពលរដ្ឋនៅឆ្ងាយពិបាកធ្វើដំណើរទៅគោរពបូជា ។ យើងពុំជឿចិនកុម្មុយនិស្ត ដែលបង្ហាញថា ប្រទេសគេមានព្រះចង្កូមកែវរបស់ព្រះពុទ្ធ ព្រោះតាមប្រវត្តិព្រះពុទ្ធសាសនា ពុំឃើញមាននិយាយថា មានព្រះចង្កូមកែវរបស់ព្រះពុទ្ធនៅប្រទេសចិនឡើយ ។

ធុរៈក្នុងពុទ្ធសាសនាមានពីរយ៉ាងគឺ គន្ថធុរៈ ការសិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ សព្វថ្ងៃនេះព្រះសង្ឃខ្មែរកំពុងសិក្សាហៅថាពុទ្ធិកសិក្សា, វិបស្សនាធុរៈ ការប្រតិបត្តិតាមពាក្យរបស់ព្រះអង្គរហូតសំរេចមគ្គផលនិព្វាន, ធុរៈនេះមានព្រះសង្ឃខ្មែរកំពុងប្រតិបត្តិនៅតាមកន្លែងនានានៃប្រទេសកម្ពុជា ។ ធុរៈទាំងពីរនេះត្រូវតែអនុវត្តដើម្បីរំដោះទុក្ខនិងដើម្បីបំពេញកិច្ចក្នុងពុទ្ធសាសនាឲ្យបានពេញលេញ ។ ព្រះសង្ឃដែលកំពុងសិក្សារៀនសូត្រពុំមែនបានន័យថា លោកកំពុងប្រតិបត្តិវិបស្សនាធុរៈទេ គឺលោកជាអ្នកមានសីលតាមលក្ខណៈជាសាមណេរនិងសង្ឃហើយ ប៉ុន្តែលោកពុំទាន់បានប្រតិបត្តិសមថៈកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋានឲ្យបានពេញលេញដោយជាប់ការសិក្សា ។ អ្នកសិក្សាផ្នែកពុទ្ធិកសិក្សានិងផ្នែកធម្មវិន័យមានប្រយោជន៍ណាស់ សំរាប់អភិវឌ្ឍន៍ព្រះពុទ្ធសាសនាឲ្យបានចំរើនលូតលាស់ ។ បើព្រះសង្ឃសមណសិស្សសមណនិស្សិតមានការចេះដឹងច្រើន ជាការបណ្តុះធនធានមនុស្ស គឺព្រះសង្ឃអ្នកចេះដឹងអាចជួយពន្យល់បំភ្លឺស្មារតីខ្មែរ ឲ្យយល់អំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និងជួយសង្គមជាតិក្នុងផ្នែកសីលធម៌ និងសង្គមកិច្ច ។ លោកមានសមត្ថភាពសរសេរសៀវភៅធម៌អាថ៌ និងពាក្យរំលឹកទូន្មានផ្សេងៗ ដើម្បីឲ្យខ្មែរសំបូរឯកសារ ផ្តល់ចំណេះដឹងឲ្យខ្មែរតាមរយៈការអានសៀវភៅទាំងនោះ ។ ចំណែកព្រះសង្ឃមួយផ្នែកទៀត បានប្រតិបត្តិធម៌ជាសមាធិឬវិបស្សនា នៅតាមអាស្រមនានាក្នុងប្រទេសកម្ពុជា ក៏ពុំគួរទៅរិះគន់ព្រះសង្ឃអ្នកសិក្សាដែរ ព្រោះដោយសារព្រះសង្ឃសិក្សាតាមចំណេះដឹងនេះហើយ បានជាសំបូរក្បួនច្បាប់ព្រះពុទ្ធសាសនា ដែលអាចឲ្យអ្នកចំរើនវិបស្សនាយកមកអាន ដើម្បីជំនួសក្នុងការប្រតិបត្តិធម៌ ។

អំពីបញ្ហាពាក់និងពាក់ទ្រនាប់ជើង មានព្រះសង្ឃនៃអាស្រមដែលប្រតិបត្តិធម៌ខ្លះ មិនកាន់បច្ច័យនិងមិនពាក់ទ្រនាប់ជើង បើធ្វើបានដូច្នេះជាការប្រសើរហើយ ប៉ុន្តែកុំឲ្យនិយាយប៉ះពាល់ដល់ព្រះសង្ឃដែលមិនបានអនុវត្តដូច្នេះ ។ រឿងពាក់ទ្រនាប់ជើងនេះ បើព្រះសង្ឃធ្វើធុតង្គដើរក្នុងព្រៃ ព្រះពុទ្ធមានពុទ្ធានុញ្ញាតឲ្យព្រះសង្ឃពាក់ទ្រនាប់ជើងពីរជាន់ទៅបួនជាន់ ព្រោះខ្លាចជាន់បន្លា កាលណាជាន់បន្លាមុតព្រះបាទនាំឲ្យមានជម្ងឺកាលណាមានជម្ងឺឬមានអាពាធ ពុំអាចដើរធ្វើធុតង្គបានឡើយ ។ ក្រៅពីនោះ ការពាក់ទ្រនាប់ជើងដើរតាមផ្លូវធម្មតា ថាត្រូវអាបត្តិទុក្កដ ជាអាបត្តិតូចបំផុត ។ រឿងអាបត្តិទុក្កដនេះ មិនថាពាក់ទ្រនាប់ជើងទេដែលត្រូវអាប

ត្តិនេះ គឺគ្រាន់តែងាកខ្លួនមិនសមបន្តិច ក៏ត្រូវអាបត្តិទុក្កដដែរ ។ បើពាក់ទ្រនាប់ជើងមិនបានត្រូវអាបត្តិទុក្កដ ការជិះយន្តយានគ្រប់ប្រភេទ ដូចជាយន្តហោះ រទេះភ្លើង រថយន្ត ទូកកាណូតកប៉ាល់ ស៊ីក្លូ ម៉ូតូ រទេះសេះ រទេះគោជាដើម ពុំអាចជិះបានឡើយ ព្រោះគ្មានវិន័យរបស់ព្រះពុទ្ធអនុញ្ញាតឲ្យជិះបានឡើយ ។ ប៉ុន្តែអាចជិះបាន ដោយគ្រាន់តែសំដែងនូវភាពជាអ្នកមានជម្ងឺ គឺធ្វើដំណើរផ្លូវឆ្ងាយ អាចហាត់ហេវមានជម្ងឺ កាលណាមានជម្ងឺពុំអាចប្រតិបត្តិធម៌បានឡើយ ។ យ៉ាងណាមិញ ការពាក់ទ្រនាប់ជើងពុំមែនដើម្បីលំអទេ គឺដើម្បីការពារកុំឲ្យមានជម្ងឺ និងដើម្បីឲ្យមានអនាម័យកុំឲ្យក្រខ្វក់ ដូចដើរតាមផ្លូវមានគ្រោះមានថ្មត្រូវមុតជើង កន្លែងចាក់កៅស៊ូត្រូវក្តៅព្រះបាទរលាកជើង កន្លែងមានភក់មានជ្រាំដើរទៅប្រឡាក់ព្រះបាទ ។ បើពាក់ទ្រនាប់ជើងមិនបាន ការស្លៀកស្បង់គ្រោងចីពរក៏ពុំបានដែរ ក៏ដូចគ្នានឹងការគង់នៅក្នុងកុដិក៏ពុំបានដែរ ប៉ុន្តែអាចប្រើប្រាស់នឹងគង់បាន បើពិចារណាតាមធម៌បច្ចវេក្ខណញ្ញាណថា ការប្រើប្រាស់ស្បង់ចីពរនិងនៅក្នុងកុដិ ដើម្បីបិទបាំងកេរ្តិ៍ខ្មាស់ ការពារខ្យល់កំដៅថ្ងៃ សត្វតូចតាចសត្វធំ វាទិចវាខាំជាដើម ។ បើតាមន័យនេះ ទ្រនាប់ជើងអាចពាក់បាន បើសំដែងភាពជាអ្នកមានជម្ងឺនិងភាពមានអនាម័យដូចពោលមកហើយ ។ បើពាក់ទ្រនាប់ជើងមិនបាន, ការបាំងឆ័ត្រការពារកំដៅថ្ងៃការពារភ្លៀងក៏ពុំបានដែរ ។ ព្រះពុទ្ធបានត្រាស់ដឹងកន្លងទៅបានជាង ២៥០០ឆ្នាំកន្លងមកហើយ មកដល់ពេលនេះវិទ្យាសាស្ត្របានលូតលាស់ចំរើន ដែលសម្ភារៈខ្លះក្នុងសម័យពុទ្ធកាលពុំទាន់កើតមាន ដូចជាព្រះសង្ឃសម័យដើមលូកព្រះហត្ថឆាន់ចង្ហាន់ក្នុងបាត្រ ឥឡូវនេះព្រះសង្ឃឆាន់ចង្ហាន់ដោយប្រើស្លាបព្រានិងសមជាដើម ។ បើព្រះអង្គគង់នៅរហូតមកដល់ពេលនេះ ហើយទតឃើញហេតុការណ៍ដូចពោលមកខាងលើនេះ ព្រះអង្គពិតជាអនុញ្ញាតក្នុងការពាក់ទ្រនាប់ជើងនេះពុំខាន ។ បើពាក់ទ្រនាប់ជើងទៅ មិនបាច់ឲ្យគេយកទឹកទៅលាងព្រះបាទឲ្យពិបាកគេទេ, ការលាងព្រះបាទ ព្រោះព្រះសង្ឃមិនពាក់ទ្រនាប់ជើងមានព្រះបាទក្រខ្វក់ ដោយដើរជាន់លើដីផ្ទាល់ គេមិនប្រគេនឲ្យជាន់លើអាសនៈដ៏ល្អរបស់គេទេ មុនពេលដែលលាងសំអាតព្រះបាទដ៏ក្រខ្វក់នោះឲ្យស្អាតសិន ។ សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធ ពុំមែនស្ថិតនៅលើការពាក់ទ្រនាប់ជើង ឬមិនពាក់នោះទេ គឺស្ថិតនៅលើការលះបង់អំពើអាក្រក់វិញទេ ។ មួយទៀតពុំដូចអ្នកខ្លះពោលថា អាបត្តិទុក្កដរួមគ្នាច្រើនទៅក្លាយជាអាបត្តិទុក្កដបារាជិកនោះទេ គ្មានវិន័យណានិយាយដូច្នេះឡើយ ។ អាបត្តិទុក្កដនៅតែជាអាបត្តិទុក្កដ ពុំអាចទៅជាអាបត្តិអ្វីផ្សេងទៀតទេ ទោះបីរួមគ្នាច្រើនរយពាន់ក៏ដោយ កុំឲ្យយល់ច្រឡំខុសវិន័យឡើយ ។ បើអ្នកមិនពាក់ទ្រនាប់ជើង ប្រព្រឹត្តខុសចិត្តមិនបរិសុទ្ធ ក៏មិនគ្រាន់បើជាងគេពាក់ទ្រនាប់ជើងដែរ ។ ដូច្នេះបញ្ហាបន្តិចបន្តួច កុំឲ្យចែកជាបក្សជាពួក នាំឲ្យបែកសាមគ្គីក្នុងសង្គមអ្នកកាន់ពុទ្ធសាសនាឡើយ ។ សូមកុំវាយតម្លៃជ្រុលថា អ្នកមិនពាក់ទ្រនាប់ជើងជាអ្នកបរិសុទ្ធឡើយ ។

អំពីបញ្ហាមិនកាន់មាសប្រាក់, គុណសម្បត្តិព្រះសង្ឃ គឺជាអ្នកមិនលោភមានសេចក្តីសន្តោស ការមានមាសប្រាក់នាំឲ្យមានសេចក្តីលោភឲ្យត្រេកអរចំពោះតែបច្ច័យ៤ គឺចីវរបច្ច័យ, បិណ្ឌបាតបច្ច័យ, សេនាសនបច្ច័យ និងគិលានភេសជ្ជបច្ច័យ ដែលជាទីអាស្រ័យរបស់អ្នកបួសខានពុំបាន ។ បើមានអ្នកឧបត្ថម្ភហើយ ព្រះសង្ឃមិនបាច់កាន់បច្ច័យដែលហៅថាជាប្រាក់ក៏ល្អហើយ ដូចជាព្រះសង្ឃកន្លែងសមាធិនិងកន្លែងវិប-ស្សនាខ្លះ ប៉ុន្តែកុំឲ្យនិយាយប៉ះពាល់ដល់ព្រះសង្ឃដែលកាន់ប្រាក់នេះ ។ អាបត្តិបាចិត្តិយៈធំជាងអាបត្តិទុក្កដបន្តិចប៉ុណ្ណោះដែលព្រះពុទ្ធហាមព្រោះដើម្បីកុំឲ្យព្រះសង្ឃជាប់ចិត្តក្នុងន័យលោភ ។ មិនថាតែមាសប្រាក់ទេ សូម្បីព្រះសង្ឃមានបច្ច័យ៤ដែលគេប្រគេនច្រើនហើយជាប់ចិត្ត ក៏មានលក្ខណៈដូចគ្នា ។ អង្គរបស់មាសប្រាក់មាន៣គឺ ១-មាសប្រាក់, ២-ទុកដាក់ជារបស់ខ្លួន, ៣-ត្រេកអរចំពោះមាសប្រាក់នោះ ។ បើព្រះសង្ឃមិនកាន់ប្រាក់ទេ ឲ្យគេទុកដាក់ឲ្យ តែត្រេកអរចំពោះមាសប្រាក់ដែលគេទុកដាក់ឲ្យនោះ ក៏មានលក្ខណៈដូចជាព្រះសង្ឃកាន់ផ្ទាល់ដែរ ។ បើព្រះសង្ឃកាន់បច្ច័យសំរាប់កសាងខ្វះអង្គមួយ គឺទុកដាក់ជារបស់ខ្លួន។ ប្រាក់នេះជាតំណាងបច្ច័យ៤ ពេលដែលសម្តេចព្រះសង្ឃរាជជួន-ណាតគង់នៅ បានមានថេរដីកាថា សម័យនេះជៀសពុំរួចពីការកាន់បច្ច័យទេ បើមិនដូច្នោះទេ ព្រះសង្ឃមិនអាចរស់នៅបានទេ ដូច្នេះបើព្រះសង្ឃណាមានមធ្យោបាយមិនកាន់បាន សូមកុំរិះគន់អ្នកកាន់ កុំឲ្យបែកបក្សពួក ព្រោះព្រះសង្ឃបុថុជ្ជនគ្មានបរិសុទ្ធជាងគ្នាទេ ។៚